**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧០ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបន្ថែមសមាសភាពក្នុងគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការបង្កើតខេត្តត្បូងឃ្មុំ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

www.pheakdeylaw.com

- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤១ សសរ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបន្ថែមសមាសភាពក្នុងគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ ដែលរួមមានដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ញឹ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ២-ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៣-ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ៅ ម៉ុនណារិន** | អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |
| ៤-ឯកឧត្តម **ឡាន់ នន** | ប្រធានក្រុមប្រឹក្សាខេត្តកំពង់ចាម | សមាជិក |
| ៥-ឯកឧត្តម **សេង យូអ៊ាន់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ផ្នែករដ្ឋបាលស៊ីវិល) ក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ ២.-**

ត្រូវបានបន្ថែមសមាសភាពក្នុងអនុគណៈកម្មការសិក្សារៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងអនុគណៈកម្មការសិក្សារៀបចំរចនាសម្ព័ន្ធរដ្ឋបាល និងធនធានមនុស្ស ចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ ដែលរួមមានដូចខាងក្រោម :

ក-<u>អនុគណៈកម្មការសិក្សារៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ</u>

| | | |
|---|---|---|
| ១-ឯកឧត្តម **ញឹ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ២-រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | | សមាជិក |
| ៣-រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | | សមាជិក |
| ៤-រដ្ឋលេខាធិការក្រសួងបរិស្ថាន | | សមាជិក |
| ៥-រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |
| ៦-រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ៧-រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | សមាជិក |
| ៨-រដ្ឋលេខាធិការក្រសួងទេសចរណ៍ | | សមាជិក |

www.pheakdeylaw.com

៩-ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ៅ ម៉ិនណារិន** អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ — សមាជិក

១០-ឯកឧត្តម **សេង យូអ៊ាន់** អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ផ្នែករដ្ឋបាលស៊ីវិល) ក្រសួងមហាផ្ទៃ — សមាជិក

ខ-<u>អនុគណៈកម្មការសិក្សារៀបចំរចនាសម្ព័ន្ធរដ្ឋបាល និងធនធានមនុស្ស</u>

១-ឯកឧត្តម **ត្រាច់ ចន្ទ** ទីប្រឹក្សារាជរដ្ឋាភិបាល — អនុប្រធាន

២-ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស — សមាជិក

៣-ឯកឧត្តម **ឡាន់ ឆន** ប្រធានក្រុមប្រឹក្សាខេត្តកំពង់ចាម — សមាជិក

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ និងប្រការ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com